ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ ៖ ១១/០៥ ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គមមានកិត្តិយសសូមជម្រាបដល់លោកឧកញ៉ា លោក លោកស្រី ឬ អ្នកតំណាងនៃសហគ្រាស គ្រឹះស្ថានទាំងអស់បានជ្រាបថា កន្លងមកមានសហគ្រាស គ្រឹះស្ថានមួយចំនួន បានបញ្ជូនកម្មករនិយោជិតដែលទទួលរងគ្រោះ ឬ មានជំងឺដូចជាជំងឺក្រពះ, គ្រុនក្តៅ ... ធ្ងន់ធ្ងរ បណ្តាលឱ្យអ្នកជំងឺឈឺចុកចាប់ខ្លាំង ឬសន្លប់នៅកន្លែងធ្វើការ ដែលករណីនេះមិនអាចចាត់ទុកជាគ្រោះថ្នាក់ការងារនោះទេ ប៉ុន្តែសហគ្រាស គ្រឹះស្ថានបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ដែលទទួលស្គាល់ ដោយ ប.ស.ស ដោយមិនបានទូទាត់សោហ៊ុយព្យាបាលសងមកប.ស.ស វិញទេ។

ក្នុងករណីដែលកម្មករនិយោជិតមានអាការៈឈឺចុកចាប់ខ្លាំង ឬសន្លប់នៅកន្លែងធ្វើការ ហើយ លោកឧកញ៉ា លោក លោកស្រី ឬអ្នកតំណាងសហគ្រាស គ្រឹះស្ថានយល់ថា ករណីនេះជាគ្រោះថ្នាក់ការងារ ហើយបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យដែលទទួលស្គាល់ដោយប.ស.ស នោះ បន្ទាប់ពីប.ស.ស ធ្វើការអង្កេតឃើញថាជាជំងឺ ឬគ្រោះថ្នាក់មិនពាក់ព័ន្ធនឹងការងារទេនោះ ការចំណាយសោហ៊ុយព្យាបាល ត្រូវស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់លោកឧកញ៉ា លោក លោកស្រីជាម្ចាស់ ឬនាយកនៃសហគ្រាស គ្រឹះស្ថាន ហើយក្នុងករណីនេះ ប.ស.ស នឹងទាមទារការទូទាត់សងតាមថ្លៃជាក់ស្តែងរបស់មន្ទីរពេទ្យ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកឧកញ៉ា លោក លោកស្រី ឬអ្នកតំណាងនៃសហគ្រាស គ្រឹះស្ថានទាំងអស់មេត្តាជ្រាប និងអនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ២០០៨
ប្រធានអគ្គនាយកបេឡាជាតិរបបសន្តិសុខសង្គម

អ៊ុក សមវិទ្យា

អាគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ Tel: (023) 882 623, (023) 882 434